# សារាចរលេខ

# ០១២

# ធ្វើពីការដោះស្រាយ

# ខាងការពារ

ណែនាំនិងឧបត្ថម្ភដោយ

-ឯកឧត្តម ជីវ សុខហាក់

-ឯកឧត្តម ប៊ុន ហុន ចំនួន៨00$

-ឯកឧត្តម កើត រិទ្ធ

-លោក តាន់ សេណារ៉ុខ

ឯកសារនេះត្រូវបានការពារ
ដោយច្បាប់នៃព្រះរាជាណា-
ចក្រកម្ពុជាតាមមាត្រា៣និង
មាត្រា១១ នៃច្បាប់ស្តីពីម៉ាក
ពាណិជ្ជនាម និងអំពើនៃការ
ប្រកួតប្រជែងមិនស្មោះត្រង់
ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MOSALVY

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ: ១៧ សកបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០០២

# ស ា រ ា ច រ

## ស្តីពី

## ការដោះស្រាយវិវាទការងារ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបលោក លោកស្រីជាម្ចាស់ និងជានាយកសហគ្រាស គ្រឹះស្ថាន បងប្អូនកម្មករនិយោជិត និងអង្គការវិជ្ជាជីវៈនានា ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ ហើយមានទីតាំងធ្វើការងារនៅក្នុងរាជធានីភ្នំពេញបានជ្រាបថា ចាប់ពីពេលនេះតទៅនៅពេលមានវិវាទការងារកើតឡើងទាំងវិវាទការងាររួម ទាំងវិវាទបុគ្គល សូមអស់លោក លោកស្រីជូនដំណឹងឬដាក់ពាក្យបណ្តឹងទៅប៉ុស្តិ៍អធិការកិច្ចការងារនៅតាមខ័ណ្ឌដែលសហគ្រាស គ្រឹះស្ថានរបស់ខ្លួនស្ថិតនៅ ដើម្បីមន្ត្រីអធិការកិច្ចការងារនៅតាមប៉ុស្តិ៍ពិនិត្យ និងដោះស្រាយវិវាទការងារនោះបានឆាប់រហ័សជាង ។ ប៉ុស្តិ៍អធិការកិច្ចការងារទាំងនោះមានអាសយដ្ឋាន ដូចមាននៅក្នុងឧបសម្ព័ន្ធជូនភ្ជាប់ជាមួយ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រីជាម្ចាស់ និងជានាយកសហគ្រាស គ្រឹះស្ថាន បងប្អូនកម្មករនិយោជិត អង្គការវិជ្ជាជីវៈដែលស្ថិតនៅក្នុងខ័ណ្ឌសីមានៃរាជធានីភ្នំពេញ ច្បាស់ជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារខាងលើបានល្អប្រសើរពុំខាន ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**អ៊ិត សំហេង**

**<u>ចម្លងជូន</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
-សាលាក្រុងភ្នំពេញ
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច

ឧបសម្ព័ន្ធនៃសារាចរ

លេខ: ១៧ សកបយ. ចុះថ្ងៃទី០៥ ខែ កក្កដា ឆ្នាំ២០០២

ស្តីពីការដោះស្រាយវិវាទការងារ

## អាសយដ្ឋានប៉ុស្តិ៍អធិការកិច្ចការងារតាមខណ្ឌនៃរាជធានីភ្នំពេញ

១-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌមានជ័យ: នៅសាលាខណ្ឌមានជ័យ ផ្ទះលេខ ០៣ , ផ្លូវលេខ៣៦១, ភូមិព្រែក សង្កាត់ច្បារអំពៅទី១ លេខទូរស័ព្ទទំនាក់ទំនង ០១៦. ៨៨៥ ០០៥- ០១២ .៨៤៥ ២១៤។

២-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌចំការមន: នៅសាលាខណ្ឌចំការមន ផ្ទះលេខ១៦៩, ផ្លូវម៉ៅសេទុង, ភូមិ១ សង្កាត់បឹងកេងកងទី៣ លេខទូរស័ព្ទទំនាក់ទំនង ០១២. ៨៧២ ៥៦៥- ០១២. ៨៣៦ ១០៥។

៣-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌដង្កោ: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១២. ៩៤៥ ០៥៥- ០១១. ៨៧៣ ៧៨៧។

៤-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌឫស្សីកែវ: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១៦. ៨៨០ ២០៩- ០១១. ៩៧៣ ២៩៥។

៥-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌទួលគោក: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១២. ៩២០ ៨៤៩- ០១១. ៨៧២ ៩៧២។

៦-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌដូនពេញ: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១២. ៨៦៨ ៣៧៧។

៧-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌ៧ មករា: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១៦. ៨៩៧ ៩៣៥។